# ការស្តាប់យ៉ាងយកចិត្តទុកដាក់ និង ភាសាកាយវិការ ជួយឲ្យទំនាក់ទំនងមានប្រសិទ្ធភាព

## ការទំនាក់ទំនងល្អ ចាប់ផ្តើមពីការស្តាប់ដោយយកចិត្តទុកដាក់



1. មើលភ្នែកអ្នកនិយាយ ដើម្បីបង្ហាញការគោរព
2. បង្ហាញថាអ្នកកំពុងស្តាប់ និងយល់ពីអ្នកនិយាយ
3. កុំរំខានពេលអ្នកដទៃកំពុងនិយាយ

## ប្រើកាយវិការសមរម្យ និងមានការគោរព





- ✗ កាយវិការខឹង ឬរឹងទទឹង អាចបង្កជម្លោះ
- ✗ កាយវិការមិនអើពើ មិនអាចជួយដោះស្រាយបានទេ

- ✓ កាយវិការទន់ភ្លន់ និងសុភាពរាបសា ជួយឲ្យមានទំនាក់ទំនងល្អ

# ប្រភេទនៃការទំនាក់ទំនង

## ការទំនាក់ទំនងបែបឈ្លានពាន និងស្ទាក់ស្ទើរ អាចបង្កជម្លោះ និងការមិនពេញចិត្តក្នុងការងារ



### ការទំនាក់ទំនងបែបបំពាន

- ប្រើពាក្យប្រមាថឬនិយាយមិនគួរអោយគោរព
- រំខានពេលអ្នកដទៃកំពុងនិយាយ
- ស្រែក ឬនិយាយបែបគំរាម
- ខឹងខ្លាំង ឬបង្ហាញអារម្មណ៍ខឹងភ្លាមៗ
- សងសឹកឬធ្វើអ្វីដើម្បីប៉ះពាល់អ្នកដទៃ



### ការទំនាក់ទំនងបែបស្ទាក់ស្ទើរ

- សុំទោសជាញឹកញាប់
- មិនហ៊ានបង្ហាញមតិយោបល់
- ជៀសវាងការប្រឈមមុខ
- មិនហ៊ានមើលភ្នែកអ្នកដទៃ
- និយាយសំឡេងតិចៗ

## ការទំនាក់ទំនងបែបអះអាង ជួយឲ្យមានការយល់ព្រម និងទំនាក់ទំនងល្អ

### ទំនាក់ទំនងបែបអះអាង

- និយាយដោយបើកចំហនិងស្ងប់ស្ងាត់
- ស្មោះត្រង់ និងមានភាពមុតមាំ
- ប្រើកាយវិការដែលសមរម្យ
- គោរពចន្លោះផ្ទាល់ខ្លួនរបស់អ្នកដទៃ
- និយាយច្បាស់ៗនិងងាយយល់
- ធ្វើកិច្ចព្រមព្រៀងដែលទាំងពីរភាគីអាចអនុវត្តបាន



# ការគ្រប់គ្រងស្ត្រេស និង ដោះស្រាយបញ្ហា

ស្ត្រេស គឺជាស្ថានភាពអារម្មណ៍ និងចិត្តមិនស្ថិតស្ថេរ ដែលកើតឡើងដោយសម្ពាធការងារ បញ្ហាជីវិត ឬបញ្ហាគ្រួសារ



ស្ត្រីភាគច្រើនមានស្ត្រេស ពីព្រោះមានទំទួលខុសត្រូវទាំងការងារ និងគ្រួសារ ចំណែកបុរសភាគច្រើនមានស្ត្រេស ពីសម្ពាធការងារ និងការរំពឹងរំពឹងទុកពីសង្គម

**ស្ត្រេសអាចនាំឲ្យមានជម្លោះ អំពើហិង្សា និងការរំលោភបំពាននៅកន្លែងធ្វើការ និងនៅក្នុងគ្រួសារ**

## ជំហានទាំង៤ អាចជួយដោះស្រាយបញ្ហាពេលមានស្ត្រេស

- ស្ងប់ស្ងាត់ និងមិនប្រតិកម្មភ្លាមៗ
- កំណត់បញ្ហា
- រកដំណោះស្រាយដែលអាចធ្វើបាន
- ស្វែងរកជំនួយពីអ្នកដទៃ

## របៀបគ្រប់គ្រងស្ត្រេស

- គេងឲ្យបានគ្រប់គ្រាន់
- ហាត់ដកដង្ហើមវែងៗ
- ធ្វើលំហាត់ប្រាណជារៀងរាល់ថ្ងៃ ដូចជា ធ្វើកាយវិការពេលធ្វើការ
- បរិភោគអាហារមានតុល្យភាព និង ជៀសវាងហូបស្ករច្រើនពេក

# សមភាពយេនឌ័រធានាថា មនុស្សគ្រប់ភេទ មានសិទ្ធិ និងឱកាសស្មើៗគ្នា សម្រាប់ស្ត្រី បុរស និងមនុស្សដែលមិនកំណត់ភេទ

## មនុស្សគ្រប់ភេទមានសិទ្ធិ និងឱកាសស្មើៗគ្នា



គ្រប់ភេទ ត្រូវតែបានប្រាក់ខែ
ស្មើៗគ្នា សម្រាប់ការងារដូចគ្នា



កុមារី កុមារា និងកុមារមិនកំណត់ភេទ
អាចលេងគ្រប់កីឡាបាន



បុរសអាចយំ និងបង្ហាញ
អារម្មណ៍សោកសៅ



អាពាហ៍ពិពាហ៍ គឺជា
ការព្រមព្រៀងគ្នា



បុរសអាចធ្វើការងារផ្ទះ



ស្ត្រីអាចជាមេដឹកនាំល្អ




ទទួលស្គាល់កុមារគ្រប់រូប ដោយ
មិនកំណត់ភេទ



មនុស្សគ្រប់ភេទអាចលេង
របស់លេងអ្វីក៏បាន



សមាជិកគ្រប់រូបក្នុងគ្រួសារអាច
សម្រេចចិត្តផ្នែកហិរញ្ញវត្ថុ



បុរស និងស្ត្រីអាចផ្តល់
ការថែទាំបានល្អដូចគ្នា

riseequal.org

RISE

# តើអ្នកអាចធ្វើអ្វីបានខ្លះពេលមានអំពើហិង្សា និងការរំលោភបំពានផ្អែកលើយេនឌ័រ?

អំពើហិង្សាផ្អែកលើយេនឌ័រ មានន័យថា ការធ្វើបាប និងការរំលោភបំពានលើមនុស្សម្នាក់ទៀត ដោយសាភេទមួយប្រើអំណាចលើភេទមួយទៀត។ អំពើហិង្សា និងការរំលោភបំពានផ្អែកយេនឌ័រ គឺជាការបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

**អំពើហិង្សា និងការរំលោភបំពានផ្អែកលើយេនឌ័រ រួមមាន៖**

### ហិង្សាផ្លូវកាយ

ការប្រើកម្លាំងផ្លូវកាយដូចជាវាយដំ រុញច្រានឬទាត់ធាក់បង្អាប់

### ហិង្សាផ្លូវចិត្ត

ការគ្រប់គ្រងខ្លាំងជ្រុល សំដីប្រមាថ និងការមើលងាយ

### ហិង្សាផ្លូវភេទ

ការបង្ខំ មិនមានការអនុញ្ញាត  ការរួមភេទដោយបង្ខំ និងមានហិង្សា

### ហិង្សាផ្អែកសេដ្ឋកិច្ច

មិនអនុញ្ញាតឲ្យប្រើប្រាស់ប្រាក់របស់ខ្លួន ឬសិទ្ធិធ្វើការសម្រេចចិត្តផ្អែកហិរញ្ញវត្ថុ

**គ្រប់ប្រភេទនៃអំពើហិង្សា ឬការរំលោភបំពាន មិនអាចទទួលយកបាន ហើយត្រូវចូលរួមបញ្ឈប់ភ្លាមៗ**

## តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីការពារកុំអោយមានអំពើហិង្សា និងការរំលោភបំពានផ្អែកលើយេនឌ័រ?

- ស្គាល់ទម្រង់នៃអំពើហិង្សាទាំង៤ប្រភេទ
- ចូលរួមបញ្ឈប់អំពើហិង្សាប្រសិនបើអ្នកឃើញវា
- កុំបន្ទោសអ្នករងគ្រោះ
- ណែនាំអ្នករងគ្រោះទៅទទួលសេវាគាំទ្រ និងការសង្គ្រោះ និងគាំទ្រផ្នែកអារម្មណ៍
- ធ្វើការរាយការណ៍ពីករណីហិង្សានេះ

## ស្វែងរកជំនួយពីហូតឡាញ (Hotline)

**1288 & 117**

ទំនាក់ទំនងទាំងនេះអាចជួយជនរងគ្រោះ ឬដំណោះស្រាយផ្សេងៗទៀត។

# ច្បាប់ និងបទបញ្ញាត នៃការដោះស្រាយ អំពើហិង្សា និងការរំលោភបំពានតាមយេនឌ័រ នៅកន្លែងធ្វើការ

## ការអនុវត្តតាមច្បាប់ការងារនៃកម្ពុជា (ច្បាប់ការងារឆ្នាំ 1997) និយាយពីការជួបប្រទះ និងអំពើហិង្សានៅកន្លែងធ្វើការ

បង្កើតការយល់ដឹងអំពីសិទ្ធិរបស់កម្មករ និយោជិក និងការពារការរំលោភបំពានផ្លូវភេទ និងការរើសអើងភេទ

បង្កើតគោលនយោបាយទូលំទូលាយក្នុងរោងចក្រ

ធ្វើសកម្មភាពដើម្បីបង្ការ និងដោះស្រាយអំពើហិង្សា និងការរំលោភបំពាន ផ្អែកលើយេនឌ័រ

បង្កើតគណៈកម្មការទទួលពាក្យបណ្ដឹង ស៊ើបអង្កេត និងផ្ដល់អនុសាសន៍

គណៈកម្មការនេះគួរតែមាន៖

- សមាជិកយ៉ាងហោចណាស់៥នាក់
- សមាជិកភាគច្រើនគួរជាស្ត្រី
- គួរតែមានស្ត្រីជាអ្នកដឹកនាំ
- និងគួរបន្ថែមសមាជិកពីរនាក់ទៀតពីអង្គភាពខាងក្រៅ ដែលមានជំនាញពិសេសលើបញ្ហាការរំលោភបំពានផ្សេងៗ

## និតិវិធីបណ្ដឹង៖

1. បណ្ដឹងអាចធ្វើឡើងដោយជនរងគ្រោះ ឬតាមរយៈអ្នកគ្រប់គ្រង តំណាងកម្មករ គ្រួសារ មិត្តរួមការងារ ឬសហជីប
2. បណ្ដឹងត្រូវបានដាក់នៅក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ
3. គណៈកម្មការបណ្ដឹងនឹងស៊ើបអង្កេតករណីនេះ

## របៀបដែលគណៈកម្មការបណ្ដឹងធ្វើសកម្មភាព

1. ការស៊ើបអង្កេតត្រូវធ្វើក្នុងការសម្ងាត់
   - អត្តសញ្ញាណរបស់អ្នកដើមបណ្ដឹង និងត្រូវបានរក្សាការសម្ងាត់មិនត្រូវបានបង្ហាញ
   - ការពារសុវត្ថិភាពរបស់អ្នកដើមបណ្ដឹង
2. គណៈកម្មការបណ្ដឹងនឹងរាយការណ៍នៅក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ
3. ករណីមិនអាចដោះស្រាយបាននៅកន្លែងការងារ នឹងត្រូវបញ្ជូនទៅក្រសួងការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬអាជ្ញាធរ